**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........១៦៤២.........**ក.ប/ខ.ល**
/២៣

**សារលិខិតអបអរសាទរ**

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ ភរិយា ព្រមទាំងកូនចៅ យើងខ្ញុំសូមចូលរួមអបអរសាទរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ក្នុងឱកាសដែល **ឯកឧត្តមបណ្ឌិត** ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់ចាត់តាំង ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំគណៈរដ្ឋមន្ត្រីសម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ការចាត់តាំងនេះ គឺពិតជាមានភាពស័ក្តិសមបំផុតស្របទៅនឹងគុណបំណាច់ និងស្នាដៃដ៏ធំធេងដែល **ឯកឧត្តមបណ្ឌិត** បានសម្រេចជាប្រយោជន៍ជូនជាតិ មាតុភូមិ និងប្រជាជន ជាពិសេសយុវជនខ្មែរយើងក្នុងរយៈពេលកន្លងមកនេះ។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាលនេះ យើងខ្ញុំសូមសម្តែងនូវមោទកភាព និងការគោរពកោតសរសើរដ៏ស្មោះបំផុតជូនចំពោះ **ឯកឧត្តមបណ្ឌិត** ទទួលបាននូវមហាជោគជ័យថ្មីៗបន្ថែមទៀត ក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្រដើម្បីបុព្វហេតុជាតិមាតុភូមិ ដើម្បីក្លាយជាកម្លាំងមហាសាមគ្គីដ៏រឹងមាំក្នុងនាមជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅកាន់ភាពរុងរឿង និងរីកចម្រើនបន្ថែមទៀត។

ជាថ្មីម្តងទៀត យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោះព្រំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខជូនដល់ **ឯកឧត្តមបណ្ឌិត និងលោកជំទាវ** ព្រមទាំងបុត្រាបុត្រី ជាទីស្រឡាញ់ សូមបានសមប្រកបតែសេចក្តីសុខ និងចម្រើន ព្រមទាំងពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ឹត សំហេង**

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ६៩*